លេខ ៤៦ ចេញផ្សាយថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមេសា ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


❖ កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា.................................. ទំព័រទី១
❖ ការចុះត្រួតពិនិត្យវឌ្ឍនភាពគម្រោង ACSEP តាមបណ្ដាខេត្ត........................ ទំព័រទី២
❖ កិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសលើកទី២ លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ.................................................. ទំព័រទី២
❖ កម្មវិធីពិភាក្សាស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍របស់បរធនបាលនៃបរធនបាលកិច្ចសាធារណៈ"............................................................ ទំព័រទី២
❖ ការសម្ដែងការគួរសម និងសួរសុខទុក្ខ" ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់...... ទំព័រទី៣
❖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ប្រកាសស្ដីពីវិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច"............................................................ ទំព័រទី៣
❖ ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.......................... ទំព័រទី៤
❖ សិក្ខាសាលាពិគ្រោះយោបល់ស្ដីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិត ២០២៥-២០២៨.................................................................. ទំព័រទី៤
❖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"............................................ ទំព័រទី៤
❖ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨"...... ទំព័រទី៥
❖ កម្មវិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ"........................................................ ទំព័រទី៥
❖ ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និងសូត្រមន្តលើករាសី សិរីសួស្តី ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី.............................. ទំព័រទី៦
❖ កម្មវិធីសម្សរសធម៌នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ.................................. ទំព័រទី៦
❖ កម្មវិធី "សម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវមជ្ឈមណ្ឌល APM, មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA, និងបណ្ណាល័យ សារមន្ទីរ និងបណ្ណសារដ្ឋាននៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)"........................................ ទំព័រទី៦
❖ កិច្ចប្រជុំស្ដីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និង
❖ ទិសដៅការងារបន្ត"........................................................................ ទំព័រទី៧
❖ សិក្ខាសាលាស្ដីពី "ច្បាប់កិច្ចសន្យា៖ បទពិសោធអនុវត្តន៍"............................. ទំព័រទី៧
❖ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨"................................................... ទំព័រទី៧
❖ សិក្ខាសាលាស្ដីពី"កាតព្វកិច្ចពន្ធចំពោះបរធនបាលកិច្ចនៅកម្ពុជា"...................... ទំព័រទី៨
❖ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ Money20//20 អាស៊ី (Money20/20 Asia)............ ទំព័រទី៨
❖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា" ទំព័រទី៩
❖ សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង-ប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"................................ ទំព័រទី១០
❖ សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"............................................... ទំព័រទី១០
❖ ចូលរួមទស្សនកិច្ចសិក្សាក្នុងកម្មវិធី "GITEX Asia Singapore 2025"............... ទំព័រទី១១
❖ សិក្ខាសាលាបណ្ដុះបណ្ដាល និងកសាងសមត្ថភាពស្ដីពី "បរធនបាលកិច្ចគ្រួសារ៖ ផែនការតជំនាន់".......................................................................... ទំព័រទី១១
❖ សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"........................................ ទំព័រទី១២
❖ សិក្ខាសាលាស្ដីពី "ការផ្គូផ្គងធុរកិច្ចអចលនវត្ថុនៅខេត្តព្រះសីហនុ និងយន្តការបរធនបាលកិច្ច"......................................................................... ទំព័រទី១២


## កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា

នារសៀលថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមេសា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជា **អនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព ក្រោមឱវាទនៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ចរបស់និយ័តករធានារ៉ាប់រងកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ការចុះត្រួតពិនិត្យវឌ្ឍនគម្រោង ACSEP តាមបណ្ដាខេត្ត

ចាប់ពីថ្ងៃអង្គារ ១២រោច ខែផល្គុន ដល់ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី១ ខែមេសា គ.ស.២០២៥ ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារចូលរួមជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចុះ-ត្រួតពិនិត្យវឌ្ឍនគម្រោង ACSEP នៅខេត្តសៀមរាប ឧត្តរមានជ័យ កំពង់ធំ ខេត្តព្រះវិហារ ត្បូងឃ្មុំ និងកំពង់ចាម នៅតាមបណ្ដាសហ-គមន៍កសិកម្ម សហគ្រាសកសិធុរកិច្ច កសិករផលិត និងផ្លូវថ្នល់ រួមមាន៖

១). កសិករដាំស្វាយចន្ទី ឈ្មួញប្រមូលទិញដំឡូងមី កសិករដាំដំឡូងមី កសិករចិញ្ចឹមមាន់ និងសហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទី។

២). ត្រួតពិនិត្យផ្លូវថ្នល់ក្នុងឃុំលំទងស្រុកអន្លង់វែង ផ្លូវថ្នល់ក្នុងស្រុកសង្គមថ្មី ផ្លូវថ្នល់ក្នុងឃុំសាលាវិស័យ ផ្លូវថ្នល់ក្នុងឃុំទឹកជ្រោយ និងផ្លូវថ្នល់ក្នុងឃុំអារក្សត្នោត។

បេសកកម្មនេះ មានការចូលរួមពី **លោក ឡុង ពិសិដ្ឋ ប្រធាន-ក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមការងារ តំណាងធនាគារ ADB, លោក ធេង វិបុលរិទ្ធ ប្រធានគ្រប់គ្រងគម្រោង ACSEP PIU2 និងជាតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឯកឧត្តម អ៊ឹម ចណ្ណា អនុរដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ និងជា-នាយកគម្រោង ACSEP PIU3 និងក្រុមការងារ**, តំណាងទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD), ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមានធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** ការចុះត្រួតពិនិត្យវឌ្ឍនគម្រោង ACSEP។

## កិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសលើកទី២ លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ

នាថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសលើកទី២ លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ែន ធីរុទ្ធ** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង**លោកស្រី Alissar Chaker តំណាង UNDP ប្រចាំប្រទេសកម្ពុជា** នៅសណ្ឋាគារហ្វៃហ្សៀល បាយ ម៉ារៀត ភ្នំពេញ។

កិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនធនាគារ ធនាគារជាតិនៃកម្ពុជា អង្គការជាតិ-អន្តរជាតិ ស្ថាប័នឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។



**រូបភាព៖** កិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសលើកទី២ លើសេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ។

## កម្មវិធីពិភាក្សាស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍របស់បរធនបាលនៃបរធនបាលកិច្ចសាធារណៈ"

នារសៀលថ្ងៃព្រហស្បតិ៍ ៦ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែមេសា គ.ស. ២០២៥, លោក រិន រដ្ឋា ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ (**ន.ប.ធ.**) អមដោយមន្ត្រីជំនាញ បានដឹកនាំកម្មវិធីពិភាក្សាស្ដីពី "កាតព្វកិច្ចផ្ដល់របាយ-ការណ៍របស់បរធនបាលនៃបរធនបាលកិច្ចសាធារណៈ"។ កម្មវិធីពិភាក្សានេះ មានការអញ្ជើញចូលរួមពីតំណាងក្រុមប្រឹក្សាបរធនបាល

ដែលកំពុងគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ **ន.ប.ធ.** រួមមាន បរធនបាលកិច្ចមូលនិធិគន្ធបុប្ផាកម្ពុជា, បរធនបាលកិច្ច ខ្មែរសហគ្រិន និងបរធន-បាលកិច្ច មូលនិធិអភិវឌ្ឍន៍ជំនាញ នៅទីស្តីការរបស់ **ន.ប.ធ.**។



**រូបភាព៖** កម្មវិធីពិភាក្សាស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍របស់បរធនបាលនៃបរធនបាលកិច្ចសាធារណៈ"។

## ការសម្តែងការគួរសម និងសួរសុខទុក្ខ" ឯកឧត្តម កិត្តិបរិក្សបណ្ឌិត គាត ឈន់

នារសៀលថ្ងៃអាទិត្យ ៩កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អមដោយ **ឯកឧត្តមអគ្គនាយករង** និងថ្នាក់ដឹកនាំបច្ចេកទេសបានចូលជួបសម្តែងការគួរសម និងសួរសុខទុក្ខ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៨ ដែលនឹងឈានមកដល់ក្នុងពេលឆាប់ៗខាងមុខ។



**រូបភាព៖** ការសម្តែងការគួរសម និងសួរសុខទុក្ខ" ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រកាសស្តីពីវិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមេសា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រកាសស្តីពីវិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅសណ្ឋាគារសុខា ភ្នំពេញ។ សិក្ខាសាលានេះរៀបចំឡើងដើម្បីផ្សព្វផ្សាយស្តីពី "ប្រកាសស្តីពីវិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច" ដែលបានចូលជាធរមានកាលពីថ្ងៃទី១២ ខែមីនា គ.ស.២០២៥។ ប្រកាសនេះបានកំណត់អំពីបែបបទ និងនីតិវិធីក្នុងការអនុវត្តសារពើពន្ធចំពោះបរធនបាលកិច្ច ដោយមិនបង្កើត ឬបន្ថែម ឬការកំណត់របប-ពន្ធថ្មីដោយឡែក ពីរបបសារពើពន្ធ ដែលមានរួចស្រេចនោះទេ។ ដើម្បីសម្រួលដល់ការអនុវត្ត ប្រកាសនេះបានកំណត់ឱ្យបរធនបាលជាអ្នកប្រកាសពន្ធជំនួស បរធនបាលទាយក និងអត្ថគាហកៈ។ ប្រកាសនេះក៏បានចូលរួមលើកម្ពស់អភិបាលកិច្ចល្អ និងបង្កើនទំនុកចិត្តវិនិយោគិន ដោយតម្រូវឱ្យបរធនបាលកាន់បញ្ជិកាគណនេយ្យដាច់ដោយឡែកៗពីគ្នា សម្រាប់បរធនបាលកិច្ចនីមួយៗដែលបង្កើត និងចុះបញ្ជី។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាងរបស់អគ្គនាយកដ្ឋានពន្ធដារ និងមន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានពន្ធដារ, និងថ្នាក់ដឹកនាំនិងមន្ត្រីនៃ **ន.ប.ធ.**, ព្រមទាំងថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកពាក់ព័ន្ធរបស់ក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរ-ធនបាលកិច្ច និងក្រុមហ៊ុនផ្តល់សេវាសវនកម្ម សរុបចំនួន១៩១ រូប។



**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រកាសស្តីពីវិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ត្រូវនឹងថ្ងៃទី៨ខែមេសា គ.ស.២០២៥ **ឯកឧត្តម ណើ សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន-អង្គភាព និងនិវត្តជន **កសហវ** នៅសាលាជាតិគយ។



រូបភាព៖ពិធីសំណេះសំណាលនិវត្តជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិត ២០២៥-២០២៨

នាព្រឹកថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ណើ សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិត ២០២៥-២០២៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៉ែន ធីរុត្ថ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង**នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន-អង្គភាព នៅសណ្ឋាគារ SUN & MOON Riverside។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ និងផែនការសកម្មភាពលម្អិត ២០២៥-២០២៨។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"

នារសៀលថ្ងៃពុធ ១២ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន-ក្រុមប្រឹក្សា អ.ស.ហ.**។

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំ អាណត្តិទី១ លើកទី២២ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២៥។ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច មានយុទ្ធសាស្ត្រអាទិភាពចំនួន បួនរួមមាន៖ ១. ការអភិវឌ្ឍទីផ្សារ ប្រតិបត្តិករ និងផលិតផលបរធនបាលកិច្ចថ្មីៗ, ២. ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួម, ៣. ការបង្កើតយន្តការគ្រប់គ្រង និងប្រតិបត្តិការតាមនវានុវត្តបច្ចេកវិទ្យា និង ៤. ការជំរុញនិងពង្រឹងការអនុវត្តច្បាប់ ដែលត្រូវអនុវត្តក្នុងក្របខ័ណ្ឌរយៈពេលខ្លី (២០២៥-២០២៧) រយៈពេលមធ្យម (២០២៨-២០៣១) និងរយៈពេលវែង (២០៣២-៣០៣៥)។កម្មវិធិសិក្ខាសាលានេះ បានបញ្ចូលកិច្ចពិភាក្សាស្តីពី "ទស្សនវិស័យនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ច" ដែលមានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយស ដែលសុទ្ធសឹងជាអ្នកជំនាញ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

ក្នុងវិស័យបរធនបាលកិច្ច វិស័យអចលនវត្ថុ វិស័យធនាគារនិងហិរញ្ញវត្ថុ និងធុរកិច្ច រួមមាន៖ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **ឯកឧត្តម ជូ វណ្ណៈ** អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ, **លោក សេង យ៉ាំដែន ប្រធាននាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិនៃធនាគារជាតិនៃកម្ពុជា** និង **ឧកញ៉ា លឹម តុង អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា**។ ក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយសបានផ្តោតការពិភាក្សាជាសំខាន់លើទស្សនាទានអំពីវិស័យអចលនវត្ថុ ទស្សនវិស័យនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ច និងគោលនយោបាយ និងវិធានការយុទ្ធសាស្ត្រដើម្បីជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

កម្មវិធីសិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងនិយ័តករក្រោមឱវាទ **អ.ស.ហ.**, ឯកឧត្តម លោកជំទាវ តំណាងក្រសួង/ស្ថាប័នពាក់ព័ន្ធ, តំណាងក្រុមហ៊ុនបរធនបាល, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពីនិយ័តករបរធនបាលកិច្ច។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"។

## ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨"

នាព្រឹកថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។



រូបភាព៖ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨"។

## កម្មវិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមក្នុងកម្មវិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។



រូបភាព៖ កម្មវិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ"។

## ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និងសូត្រមន្តលើករាសី សិរីសួស្តី ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី

នាព្រឹកថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការី បានអញ្ជើញចូលរួមពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និងសូត្រមន្តលើករាសី សិរីសួស្តី ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) នៅទីស្តីការ **អ.ស.ហ.**។

ពិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមប្រតិភូទទួលបន្ទុកជាអគ្គនាយក និងឯកឧត្តមអគ្គនាយកនៃនិយ័តករក្រោមឱវាទ **អ.ស.ហ.**, ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**។



រូបភាព៖ ពិធីចម្រើនព្រះបរិត្ត អបអរពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ និងសូត្រមន្តលើករាសី សិរីសួស្តី ឆ្នាំចាស់ផ្លាស់ចូលឆ្នាំថ្មី។

## កម្មវិធីសម្បុរសធម៌នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ដែលនឹងមកដល់នាពេលខាងមុខនេះ, នារសៀលថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងលោកជំទាវ រួមដំណើរដោយឯកឧត្តមអគ្គនាយករង លោក លោកស្រីជាថ្នាក់ដឹកនាំបច្ចេកទេស និងសហការីនៃ **ន.ប.ធ.** បានចុះទៅមជ្ឈមណ្ឌលទារក និងកុមារជាតិ ដើម្បីសួរសុខទុក្ខ លើកទឹកចិត្ត ចែករំលែក និងផ្តល់ក្តីស្រលាញ់ ដល់ក្មេងៗកំព្រា គ្មានអាណាព្យាបាល និងមានពិការភាពទាំងការរស់នៅ និងហូបចុក ក៏ដូចជាលើកទឹកចិត្ត និងគាំទ្រដល់បុគ្គលិកបម្រើការងារមើលថែទាំក្មេងៗ ព្រមទាំងមានការរៀបចំជាអាហារពេលល្ងាច ភេសជ្ជៈ និងប្រគល់គ្រឿងបរិភោគនិងសម្ភារៈដែលចាំបាច់ក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ជូនដល់បុគ្គលិក និងក្មេងៗនៅក្នុងមជ្ឈមណ្ឌល។



រូបភាព៖ កម្មវិធីសម្បុរសធម៌នៅមជ្ឈមណ្ឌលទារក និងកុមារជាតិ។

## កម្មវិធី "សម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវមជ្ឈមណ្ឌល APM, មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA, និងបណ្ណាល័យ សារមន្ទីរ និងបណ្ណសារដ្ឋាននៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)"

នារសៀលថ្ងៃសុក្រ ៦រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធី "សម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវមជ្ឈមណ្ឌល APM, មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA, និងបណ្ណាល័យ សារមន្ទីរ និងបណ្ណសារដ្ឋាននៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (**ARDB**)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ ARDB តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅការិយាល័យកណ្តាលថ្មីនៃធនាគារ ARDB។



រូបភាព៖ កម្មវិធី "សម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវមជ្ឈមណ្ឌល APM, មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA, និងបណ្ណាល័យ សារមន្ទីរ និងបណ្ណសារដ្ឋាននៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)"។

## កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត"

នារសៀលថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមេសា គ.ស.២០២៥ **ន.ប.ធ.** បានរៀបចំកិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញអំពីសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់ **ន.ប.ធ.** លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅត្រីមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។



រូបភាព៖ កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត"។

## សិក្ខាសាលាស្តីពី "ច្បាប់កិច្ចសន្យា៖ បទពិសោធអនុវត្តន៍"

នាព្រឹកថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក **ន.ប.ធ.** បានចូលរួមជាអធិបតី និងផ្តល់មតិបើកកម្មវិធីសិក្ខាសាលាស្តីពី "ច្បាប់កិច្ចសន្យា៖ បទពិសោធអនុវត្តន៍" ដែលសហការរៀបចំដោយ **ន.ប.ធ.** និយ័តករមូលបត្រកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានខេមអេដ នៅវិទ្យាស្ថានខេមអេដ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីកសាងសមត្ថភាពមន្ត្រីនៃនិយ័តករបរធនបាលកិច្ច, និយ័តករមូលបត្រកម្ពុជា និងនិយ័តករធានារ៉ាប់រងកម្ពុជា លើចំណេះដឹងបន្ថែមអំពីច្បាប់កិច្ចសន្យា។ កម្មវិធីនេះ មានការអញ្ជើញចូលរួមចែករំលែកដោយ **លោកបណ្ឌិត ព្រំម វីរៈ ប្រធានក្រុមប្រឹក្សាភិបាល** នៃវិទ្យាស្ថានខេមអេដ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនិយ័តករទាំង ៣។




រូបភាព៖ សិក្ខាសាលាស្តីពី "ច្បាប់កិច្ចសន្យា៖ បទពិសោធអនុវត្តន៍"។

## ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨"

នាព្រឹកថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន-អង្គភាព នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ីភ្នំពេញ។



រូបភាព៖ ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨"។

## សិក្ខាសាលាស្តីពី"កាតព្វកិច្ចពន្ធចំពោះបរធនបាលកិច្ចនៅកម្ពុជា"

នៅថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមេសា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច**នៃ **ន.ប.ធ.** និងក្រុមការងារ បានចូលរួមក្នុងសិក្ខាសាលា និងកិច្ចពិភាក្សាដែលរៀបចំដោយក្រុមហ៊ុន ឌីអេហ្វឌីអិល កម្ពុជា ក្រោមការគាំទ្ររបស់ សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាក្រោមប្រធានបទ "កាតព្វកិច្ចពន្ធចំពោះបរធនបាលកិច្ចនៅកម្ពុជា"។ កម្មវិធីនេះ រៀបចំក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងឱ្យកាន់តែនិងទូលំទូលាយអំពីបែបបទ និងវិធានអនុវត្ត សារពើពន្ធចំពោះបរធនបាលកិច្ចនៅកម្ពុជា។ តាមរយៈប្រកាសស្តីពី វិធាន និងនីតិវិធីសារពើពន្ធចំពោះបរធនបាលកិច្ច លេខ១៩២ សហវ.ប្រក.អពដ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ បានធ្វើឲ្យកម្ពុជា មានវិធានអនុវត្តសារពើពន្ធច្បាស់លាស់ចំពោះបរធនបាលកិច្ច លើកកម្ពស់អភិបាលកិច្ចល្អ និងធ្វើឱ្យយន្តការបរធនបាលកិច្ចកាន់តែមានប្រសិទ្ធភាព ក៏ដូចជា ការអនុវត្តកាន់តែច្បាស់លាស់សម្រាប់ភាគីពាក់ព័ន្ធក្នុងបរធនបាលកិច្ច។ កិច្ចពិភាក្សាក្នុងកម្មវិធីនេះ មានការចូលរួមពីតំណាងបរធនបាល អ្នកជំនាញវិជ្ជាជីវៈ វិនិយោគិន និងក្រុមហ៊ុនពាក់ព័ន្ធ នៅ សណ្ឋាគារ Raffles Hotel Le Royal រាជធានីភ្នំពេញ។



រូបភាព៖ សិក្ខាសាលាស្តីពី"កាតព្វកិច្ចពន្ធចំពោះបរធនបាលកិច្ចនៅកម្ពុជា"។

## វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ Money20//20 អាស៊ី (Money20/20 Asia)

នាថ្ងៃអង្គារ-ព្រហស្បតិ៍ ១០-១២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២-២៤ ខែមេសា គ.ស. ២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ចេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា**នៃនាយកដ្ឋានកិច្ចការទូទៅ និង**លោក ម៉េង ឈុនលី មន្ត្រីជំនាញការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា**នៃនាយកដ្ឋានកិច្ចការទូទៅ មានកិត្តិយសត្រូវបានចាត់ឱ្យចូលរួម "វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ Money20//20 អាស៊ី (Money20/20 Asia)" នៅមជ្ឈមណ្ឌលសន្និបាតជាតិ Queen Sirikit នាទីក្រុងបាងកក ប្រទេសថៃ ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology-FinTech), ក្របខណ្ឌបទប្បញ្ញត្តិ, ឧត្តមានុវត្តន៍, បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃការវិវត្ត FinTech ជាសកលក៏ដូចជាបច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។




រូបភាព៖ វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ Money20//20 អាស៊ី (Money20/20 Asia)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"

នាព្រឹកថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមេសា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា អមដោយមន្ត្រីជំនាញ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា" ដែលរៀបចំដោយនិយ័តករគណនេយ្យ និងសវនកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ខី តាឃី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា នៅសណ្ឋាគារ ភ្នំពេញ។

នៅក្នុងសិក្ខាសាលាផ្សព្វផ្សាយនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងអង្គភាពក្រោមឱវាទ **អ.ស.ហ.**, ស្ថាប័នពាក់ព័ន្ធ, សមាជិកសមាជិកានៃគណៈកម្មាធិការ, គ្រឹះស្ថានអប់រំ, និយោជិក, សិស្ស-និស្សិត និងសាធារណជន។



រូបភាព៖សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"។

## កម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៥"

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយមន្ត្រីជំនាញបានចូលរួមកម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៥" ដែលរៀបចំដោយនិយ័តករធានារ៉ាប់រងកម្ពុជា នាថ្ងៃទី២៦-២៧ ខែមេសា គ.ស.២០២៥ នៅខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី **លោក មូល ធន អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង** រដ្ឋបាលខេត្ត មន្ទីរ ដៃគូអភិវឌ្ឍន៍ សភាពាណិជ្ជកម្ម ក្រុមហ៊ុនធានារ៉ាប់រង និងស្ថាប័នពាក់ព័ន្ធនានាផងដែរ។



រូបភាព៖ កម្មវិធី "ទិវាធានារ៉ាប់រងកម្ពុជា ២០២៥"។

## ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

នាព្រឹកថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគណៈ-កម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន** គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។



រូបភាព៖ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង-ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមេសា គ.ស.២០២៥ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើក-កម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់-តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និង **លោក គង្គ ច័ន្ទណៃត នាយករងរដ្ឋបាលខេត្ត តំណាងគណៈអភិបាលខេត្តកណ្តាល** នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាល។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះដល់សមាជិក-សមាជិកាសហគមន៍កសិករ និងសហគ្រាសកសិធុរកិច្ចមួយចំនួនដែលមានបំណងស្វែងរកទុនគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាល, សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន÷ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង-ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមេសា គ.ស.២០២៥ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នល ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម ពិន វណ្ណារ៉ូ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ នៅសាកលវិទ្យាល័យហេង សំរិន ត្បូងឃ្មុំ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរ-ធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ចំនួន ២០០ រូប។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ចូលរួមទស្សនកិច្ចសិក្សាក្នុងកម្មវិធី "GITEX Asia Singapore 2025"

ចាប់ពីថ្ងៃពុធ ដល់ថ្ងៃសុក្រ ១១រោច-១៣រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ស.ព.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែមេសា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **កញ្ញា អៀង ច័ន្ទសិទ្ធីលីហ្សា អនុប្រធានការិយាល័យសហប្រតិបត្តិការ**នៃនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និង**កញ្ញា រិន វួចនា មន្ត្រីជំនាញនៃការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា**នៃនាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមទស្សនកិច្ចសិក្សាក្នុងកម្មវិធី "GITEX Asia Singapore 2025" ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងនវានុវត្តន៍ថ្មីៗ ដូចជានិន្នាការថ្មីៗនៃការវិវត្តនៃបច្ចេកវិទ្យានៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុជាសកល កិច្ចសហប្រតិបត្តិការក្នុងសេដ្ឋកិច្ចឌីជីថលអន្តរជាតិ បច្ចេកវិទ្យាបៃតង សន្តិសុខសាយប័រ និងបញ្ញាសិប្បនិម្មិតក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ម៉ូហាម អាយ គូ-វ៉ាយធី** ប្រធានសន្តិសុខសាយប័រសម្រាប់រដ្ឋាភិបាលនៃប្រទេស**អេមីរ៉ាតអារ៉ាប់រួម, លោក ដាវីត កូស ស្នងការ និងជានាយកប្រតិបត្តិ**នៃសន្តិសុខសាយប័រប្រទេសសិង្ហបុរី និង**លោកស្រី ទ្រីកស៊ី ឡូហ៍-មៀម៉ាន់ដ៍ អនុប្រធានប្រតិបត្តិ**នៃមជ្ឈមណ្ឌល លពាណិជ្ជកម្មពិភពលោកឌូបៃ នៅសណ្ឋាគារ ម៉ារីណា បៃសេនប្រទេសសិង្ហបុរី។

កម្មវិធីនេះត្រូវបានរៀបចំឡើងប្រចាំឆ្នាំតាមបណ្តាប្រទេសដែលជាដៃគូសហការរបស់កម្មវិធី រួមមាន៖ ឌូបៃ មូស្គូ អ៊ឺរ៉ុប សិង្ហបុរី ហ្វីលីពីន វៀតណាម និងថៃ ជាដើម ព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងតំណាងជាន់ខ្ពស់ដែលមកពីជុំវិញពិភពលោកដែលមានការអភិវឌ្ឍឌីជីថលជឿនលឿន មន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលតាមបណ្តាប្រទេសអន្តរជាតិ និងវិស័យឯកជន ក្នុងគោលដៅចែក-រំលែកពិសោធន៍ ការចាប់យកកាលានុវត្តភាពថ្មីៗអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាបៃតង សន្តិសុខសាយប័រ បញ្ញាប្រឈម និងអភិបាលកិច្ចបច្ចេកវិទ្យាជាសកល ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ការវិនិយោគលើឌីជីថល ការ-អភិវឌ្ឍឌីជីថល និងបញ្ញាសិប្បនិម្មិតនាពេលអនាគត។




រូបភាព៖ ចូលរួមទស្សនកិច្ចសិក្សាក្នុងកម្មវិធី "GITEX Asia Singapore 2025"។

## សិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពស្តីពី "បរធនបាលកិច្ចគ្រួសារ៖ផែនការតជំនាន់"

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយក្រុមហ៊ុនបរធនបាលហ្វីលីព ត្រាសធី (**កម្ពុជា**) និងក្រុមហ៊ុនបរធនបាលហ្វីលីព (**សិង្ហបុរី**) រៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពស្តីពី "បរធនបាលកិច្ចគ្រួសារ៖ផែនការតជំនាន់" នៅសណ្ឋាគារ សុខា ភ្នំពេញ។

កម្មវិធីសិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍ពីប្រទេសសិង្ហបុរីពាក់ព័ន្ធនឹងបរធនបាលកិច្ចគ្រួសារ មានដូចជា៖ ការបង្កើត ការប្រព្រឹត្តិទៅតួអង្គពាក់ព័ន្ធ និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងបរធនបាលកិច្ចគ្រួសារភាពធានាបាននូវស្ថិរភាពហិរញ្ញវត្ថុគ្រួសារឆ្លងជំនាន់ ព្រមទាំងមានករណីសិក្សាតាមប្រភេទនៃជម្រើស និងផលប្រយោជន៍ប្រៀបធៀបនៃការប្រើប្រាស់យន្តការនេះផងដែរ។ កម្មវិធីសិក្ខាសាលានេះ មានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសពី **លោក John Tan ជានាយក-ប្រតិបត្តិ ក្រុមហ៊ុនបរធនបាលហ្វីលីព (សិង្ហបុរី)** និង**លោក ព្រឿង សុភាព ជាអ្នកគ្រប់គ្រងទូទៅ**នៃ ក្រុមហ៊ុនបរធនបាលហ្វីលីព ត្រាសធី (**កម្ពុជា**) និង**លោក ផង់ វិចិត្រ ជាប្រធានផ្នែកច្បាប់**នៃក្រុមហ៊ុនបរ-ធនបាលហ្វីលីព ត្រាសធី (**កម្ពុជា**) ព្រមទាំងមានការចូលរួមដោយពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.**។



រូបភាព៖ សិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពស្តីពី "បរធន-បាលកិច្ចគ្រួសារ៖ផែនការតជំនាន់"។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង-ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែមេសា គ.ស.២០២៥ និយ័តករបរធន-បាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និង **ឯកឧត្តម ទុយ សុភ័ក្រ្ត** អភិបាលរងនៃគណៈអភិបាលខេត្ត តំណាងគណៈអភិបាលខេត្តតាកែវ នៅសណ្ឋាគារអាលីស ខេត្តតាកែវ។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោល-នយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះដល់សមាជិក-សមាជិកាសហគមន៍កសិករ និងសហគ្រាសកសិធុរកិច្ចមួយចំនួន ដែលមានបំណងស្វែងរកទុនគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ, សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរួមមាន÷ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង-ប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## សិក្ខាសាលាស្តីពី "ការផ្គូផ្គងធុរកិច្ចអចលនវត្ថុនៅខេត្តព្រះសីហនុ និងយន្តការបរធនបាលកិច្ច"

នារសៀលថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែមេសា គ.ស.២០២៥ **ន.ប.ធ.** បានសហការជាមួយលេខាធិការដ្ឋានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា រៀបចំសិក្ខាសាលាស្តីពី "ការផ្គូផ្គងធុរកិច្ចអចលនវត្ថុនៅខេត្ត-ព្រះសីហនុ និងយន្តការបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម អ៊ឹម សុខធី** ប្រធានលេខាធិការដ្ឋានក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ និង**លោកឧកញ៉ា សន សៀប** ប្រធាន-សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះ ត្រូវរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមរបស់ **ន.ប.ធ.** ដើម្បីចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល និងដើម្បីចូលរួមជំរុញការវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា តាមរយៈយន្តការបរធនបាលកិច្ច។ កម្មវិធីនេះ ផ្តល់ជូនវិនិយោគិន ជាពិសេសវិនិយោគិនបរទេស នូវថ្នាលដែលមានសុវត្ថិភាពនិងប្រសិទ្ធភាព ដោយអាចស្វែងរកអចលនទ្រព្យដែលមានសក្តានុពល មានមូលដ្ឋានព័ត៌មានច្បាស់លាស់ តាមរយៈអ្នកជំនាញអចលនទ្រព្យមានវិជ្ជាជីវៈខ្ពស់និងមានអាជ្ញាបណ្ណស្របច្បាប់ រហូតដល់ឈានទៅធ្វើសម្រេចចិត្តវិនិយោគ តាមរយៈការបង្កើតជាបរធនបាលកិច្ច អនុលោមតាមច្បាប់និងគាំពារដោយច្បាប់ជាធរមាន។

កម្មវិធីនេះ មានការអញ្ជើញចូលរួមដោយ **ស.វ.អ.ក** និងព្រមទាំងមានការអញ្ជើញចូលរួមពីប្រតិបត្តិករផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងវិនិយោគិនសក្តានុពល។

សូមបញ្ជាក់ផងដែរថា គិតមកទល់ពេលបច្ចុប្បន្ន ក្រោយការប្រកាសដាក់ឱ្យដំណើរការទីផ្សារបរធនបាលកិច្ចជាផ្លូវការនៅដើមឆ្នាំ-២០២៣ បរធនបាលកិច្ចអចលនទ្រព្យដែលបង្កើត និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅ **ន.ប.ធ.** មានចំនួន ៧៩៥ ករណី ជាមួយនឹងបរធនវិនិយោគប្រមាណជា ៧៧៤ លានដុល្លារអាមេរិក។ ជាមួយគ្នានេះ បរធនបាលកិច្ចសេវារក្សាទុក ឬរក្សាសុវត្ថិភាព (Escrow Services) ពាក់ព័ន្ធនឹងប្រតិបត្តិការទិញ-លក់អចលនទ្រព្យ បានកើនដល់ចំនួន ២៥១ ករណី គិតជាទំហំសាច់ប្រាក់ប្រមាណជា ៣២២ លានដុល្លារអាមេរិក។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្គូផ្គងធុរកិច្ចអចលនវត្ថុនៅខេត្តព្រះសីហនុ និងយន្តការបរធនបាលកិច្ច"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888